ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៥៥ អយក.សាណន

# សេចក្តីណែនាំ
# ស្តីពី
# ការគាំទ្រដល់ដំណើរការរៀនសូត្ររបស់សិស្សភៀសសឹក

ដើម្បីសម្រួល និងធានាដំណើរការរៀនសូត្ររបស់សិស្សភៀសសឹក ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់អង្គភាពពាក់ព័ន្ធ គ្រឹះស្ថានសិក្សាសាធារណៈ បុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូ មាតាបិតា និងអ្នកអាណាព្យាបាលទាំងអស់ ដូចខាងក្រោម៖

- **ក្រសួង**អនុញ្ញាតឱ្យសិស្សភៀសសឹកទាំងអស់ ចុះឈ្មោះចូលរៀនជាបណ្ដោះអាសន្ននៅតាមសាលារៀន ដែលនៅជិតតំបន់ភៀសសឹក ឬកន្លែងស្នាក់នៅ តាមការស្ម័គ្រចិត្ត
- **គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា** ត្រូវ
  - ចាត់ចែង និងរៀបចំក្រុមការងារជួយគាំទ្រ
  - ទទួល និងសម្របសម្រួលការចុះឈ្មោះ តាមកម្រិតថ្នាក់
  - រៀបចំថ្នាក់រៀន និងកាលវិភាគសម្រាប់សិស្សភៀសសឹក
  - ផ្តល់ការប្រឹក្សា និងលើកទឹកចិត្តជាប្រចាំដល់សិស្សភៀសសឹក
  - រៀបចំក្លឹបសិក្សាតាមមុខវិជ្ជា ដើម្បីជួយគាំទ្រ ជាពិសេសសិស្សថ្នាក់ទី៩ និងទី១២
  - រៀបចំរបាយការណ៍អំពី ការទទួលសិស្ស និងស្ថានភាពរៀនសូត្ររបស់សិស្សភៀសសឹក ។
- **មាតាបិតា និងអ្នកអាណាព្យាបាល** ត្រូវ
  - នាំកូនចៅ ទៅចុះឈ្មោះចូលរៀននៅតាមសាលារៀន ដែលនៅជិតតំបន់ភៀសសឹក ឬកន្លែងស្នាក់នៅ
  - លើកទឹកចិត្ត និងអប់រំកូនៗ ឱ្យមានស្មារតីរឹងមាំ និងផ្តោតលើការសិក្សារៀនសូត្រ។
- **មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអាជ្ញាធរពាក់ព័ន្ធ** ត្រូវ
  - ផ្តល់កិច្ចសហការ និងគាំទ្រដល់សាលារៀន នៅក្នុងអំឡុងពេលទទួលចុះឈ្មោះសិស្សភៀសសឹក ក៏ដូចជាក្នុងអំឡុងពេលនៃដំណើរការបង្រៀន និងរៀន
  - រៀបចំរបាយការណ៍អំពី ការជួយគាំទ្រសិស្សភៀសសឹក និងផ្ញើមកក្រសួងអប់រំ យុវជន និង កីឡា (អគ្គនាយកដ្ឋានអប់រំ លេខតេលេក្រាម 012883552)។



អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh

Scanned with CamScanner

ទទួលបានសេចក្តីណែនាំនេះ គ្រឹះស្ថានសិក្សាសាធារណៈ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ខណ្ឌ ស្រុក មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត លោកគ្រូ អ្នកគ្រូ និងគ្រប់ភាគីពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ៦រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី

  *"ដើម្បីជ្រាបជាព័ត៌មាន"*
- កាលប្បវត្តិ
- ឯកសារ អគ្គនាយកដ្ឋានអប់រំ



Scanned with CamScanner